# មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព

## ព្រឹត្តិប័ត្រព័ត៌មាន

លេខទី៣ | វិច្ឆិកា-ធ្នូ ២០២១



- បង្កើនការប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមរយៈយុទ្ធនាការ
- ការប្រើប្រាស់បណ្តាញសង្គម ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- ផ្សេងៗ ស្តីពីការផ្លាស់ប្តូរឥរិយាបថ និងការលើកកម្ពស់សុខភាព





# បង្កើនការប្រយុទ្ធនឹងជំងឺកូវីដ-១៩ តាមរយៈយុទ្ធនាការ

អស់រយៈពេលជិត២ឆ្នាំមកហើយ ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាល ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅថ្នាក់ក្រោមជាតិ និងសហគមន៍ បានរួមគ្នាទទួលខុសត្រូវក្នុងការបង្ការ និងឆ្លើយតបនឹងជំងឺកូវីដ-១៩ ។ ជាលទ្ធផលគឺ ប្រជាជនកម្ពុជាជាច្រើនមានការយល់ដឹង និងអនុវត្តនូវវិធានការសុខាភិបាល បង្ការជំងឺកូវីដ-១៩ ដែលរួមចំណែកធ្វើឱ្យអត្រាឆ្លងកូវីដ-១៩ ថយចុះជាបន្តបន្ទាប់ ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ដែលធ្វើឱ្យប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេស ដែលមានអត្រាអ្នកចាក់វ៉ាក់សាំងខ្ពស់នៅក្នុងពិភពលោក ដែលធ្វើឱ្យប្រទេសកម្ពុជាបើកដំណើរការសង្គម និងសេដ្ឋកិច្ចឡើងវិញ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ ។


ទោះជាយ៉ាងណាក៏ដោយ ជំងឺនេះមិនទាន់សាបសូន្យ


ទោះជាយ៉ាងណាក៏ដោយ ជំងឺនេះមិនទាន់សាបសូន្យនៅឡើងទេ ជាពិសេសមានការរាលដាលនូវពពួកបំប្លែងថ្មីដូចជា អាល់ហ្វា ដែលតា និងអូមីក្រុង ។ ជាការចាំបាច់ក្នុងការបន្តការក្រើនរំលឹកដល់ប្រជាជនកុំឱ្យធ្វេសប្រហែស បន្តអនុវត្តវិធានការសុខាភិបាល ៣ការពារ និង៣កុំ ឱ្យមានប្រសិទ្ធភាព ។ ហេតុនេះហើយ បានជា "អនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈនៃគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩" បានប្រកាសបើកនូវការអនុវត្តយុទ្ធនាការ ក្រោមប្រធានបទ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ កន្លងទៅនេះ ក្នុងគោលបំណងដើម្បីក្រើនរំលឹកពញ្ញាក់ស្មារតី និងបង្កើនជំរុញការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ព្រមទាំងបងប្អូនប្រជាពលរដ្ឋ ស្ថាប័ន-ក្រសួង

ពាក់ព័ន្ធ អង្គភាពសាធារណៈដទៃទៀត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ មន្ទីរ អង្គភាពជំនាញនានា អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសេវាឯកជនទាំងអស់ រួមគ្នាអនុវត្តវិធានការ ៣ការពារ និង៣កុំ ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

នៅក្នុងសន្និសិទសារព័ត៌មាន នៅថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល** និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានមានប្រសាសន៍ថា "ការអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាលប្រជាពលរដ្ឋឱ្យយល់ដឹងអំពីគ្រោះថ្នាក់នៃវីរុសកូវីដ-១៩ និងចេះទទួលខុសត្រូវក្នុងការការពារខ្លួនឯង គ្រួសារ និងសហគមន៍ ពិតជាមានសារៈសំខាន់ណាស់ ។ យើងបានធ្វើកិច្ចការងារនេះជាច្រើនកន្លងមកហើយ ដែលធ្វើឱ្យយើងអាចទប់ស្កាត់បានការចម្លងទ្រង់ទ្រាយធំចូលក្នុងសហគមន៍កន្លងមក ប៉ុន្តែក្នុងសភាពការណ៍នៃការរាតត្បាតនៅតែធ្ងន់ធ្ងរ ជាពិសេសក្នុងបណ្តាប្រទេសក្នុងតំបន់ ប្រទេសជិតខាងយើងដែលនៅតែបន្តយុទ្ធនាការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ប្រជា-ពលរដ្ឋ កាន់តែមានសារៈសំខាន់ជាងពេលណាទាំងអស់។"

យុទ្ធនាការ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ផ្តោតទៅលើសារគន្លឹះចំនួន៣ធំៗ គឺ ៖

១) យើងកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់បំផុតជាមួយគ្នា

២) លើកទឹកចិត្តដល់ការធ្វើតេស្តកូវីដ-១៩ ការចាក់វ៉ាក់សាំង ស្វែងរកការព្យាបាល និងការផ្លាស់ប្តូរឥរិយាបថ

៣) ទំនាក់ទំនងពិសេសសម្រាប់រដូវបុណ្យទាន អាពាហ៍ពិពាហ៍ និងពិធីផ្សេងៗ ។

យុទ្ធនាការនេះបានធ្វើឡើងនៅទូទាំងប្រទេស ដោយប្រើប្រាស់យុទ្ធសាស្ត្រពីរក្នុងការអនុវត្ត គឺ ទំនាក់ទំនងអន្តរបុគ្គល និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដោយមានសកម្មភាពជាច្រើន ទាំងនៅថ្នាក់ជាតិ នៅតាមរាជធានី-ខេត្ត និងមានការចូលរួមរបស់ក្រសួងពាក់ព័ន្ធដូចជា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងអប់រំ យុវជន និងកីឡា ។







ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ មិនមែនគ្រាន់តែជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែការងារនេះត្រូវការការចូលរួមពីប្រជាពលរដ្ឋទាំងអស់ ដូចដែល **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** បានមានប្រសាសន៍បន្ថែមទៀតថា ប្រជាជនទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តវិធានការសុខាភិបាល ៣ការពារ (ពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ លាងដៃឱ្យបានញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលលើសពី១,៥ម៉ែត្រ) និង ៣កុំ (កុំទៅកន្លែងមានមនុស្សច្រើនកុះករ កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា) ព្រមទាំងចាក់វ៉ាក់សាំងឱ្យបានឆាប់បំផុតនៅពេលដល់វេនរបស់ខ្លួន ដើម្បីចូលរួមទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ក្នុងគ្រួសារនិងសហគមន៍ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

# ការប្រើប្រាស់បណ្តាញសង្គម ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

ការរីករាលដាលនៃជំងឺកូវីដ-១៩ បានប៉ះពាល់ដល់គ្រប់ផ្នែកនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ជាពិសេសការរក្សាគម្លាត និងការមិនចូលរួមកម្មវិធីអ៊ីអរផ្សេងៗ ។ ដូច្នេះ, មនុស្សភាគច្រើនបានងាកទៅរកការប្រើប្រាស់បណ្តាញសង្គមដើម្បីទទួលបានព័ត៌មានផ្សេងៗ និងតភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិ ។

យោងតាមរបាយការណ៍សិក្សាស្រាវជ្រាវរបស់អង្គការ Save the Children ក្នុងខែឧសភា ឆ្នាំ២០២០ បានបង្ហាញឱ្យឃើញថា គ្រួសារកម្ពុជា ៩៩% មានទូរស័ព្ទដៃទំនើប (១០០% នៅទីក្រុង និង៩៨,៥% នៅជនបទ) ។ ពួកគេទាំងអស់ប្រើអ៊ិនធឺណែត តាមរយៈទូរស័ព្ទដៃចល័ត ។ លើសពីនេះទៅទៀត គ្រួសារកម្ពុជាភាគច្រើន (៩៧%) មានគណនីហ្វេសប៊ុក (៩៨% នៅទីក្រុង និង ៩៥% នៅជនបទ) ។

នេះបញ្ជាក់ថា បណ្តាញសង្គមមានហ្វេសប៊ុកជាដើមជាឧបករណ៍ដ៏សំខាន់ក្នុងការផ្សព្វផ្សាយសារផ្សេងៗដល់សាធារណជនឱ្យបានច្រើនក្នុងពេលតែមួយ និងយ៉ាងឆាប់រហ័ស ។ បណ្តាញសង្គមក៏បានក្លាយទៅជាវេទិកា ដែលប្រជាជនគ្រប់រូបអាចពិភាក្សានិងស្វែងរកព័ត៌មានទាក់ទងនឹងសុខភាព ដែលអាចផ្តល់អំណាចដល់គេក្នុងការវិភាគនិងវាយតម្លៃហានិភ័យចំពោះមុខទាក់ទងនឹងសុខភាពរបស់ខ្លួន និងគ្រប់គ្រងអារម្មណ៍ក្នុងពេលមានការរីករាលដាលនៃជំងឺក្នុងពិភពលោក ។

ក្រសួងសុខាភិបាលយល់យ៉ាងច្បាស់នូវអត្ថប្រយោជន៍នៃបណ្តាញសង្គម ព្រមទាំងបានប្រើប្រាស់បណ្តាញសង្គមក្នុងការអប់រំប្រជាជន តាំងពីមានការរីករាលដាលដំបូងនៃជំងឺកូវីដ-១៩ ។ ឧទាហរណ៍ជាក់ស្តែង កាលពីឆ្នាំ២០២០ មជ្ឈមណ្ឌលជាតិបានដឹកនាំការផលិតសម្ភារអប់រំអំពីជំងឺកូវីដ-១៩ ក្នុងការក្រើនរំលឹកប្រជាជនជាហូរហែ ដូចជាក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរជាដើម ។ ដើម្បីប្រាកដថា សារដែលបញ្ជូនទៅប្រជាជនពិតជាទទួលបានការចាប់អារម្មណ៍ពីសាធារណជន វីដេអូដែលបង្កើតសម្រាប់អប់រំ ក្នុងបណ្តាញ




*មតិរបស់អ្នកប្រើប្រាស់ហ្វេសប៊ុក កាលពីខែមេសា ឆ្នាំ២០២០*




សង្គម ផ្តោតលើប្រធានបទ២ គឺ "ទេវតា" និង "ផ្កាយ" ដែលជានិមិត្តរូបនៃការប្រោះព្រំ សុំពរជ័យ សិរីសួស្តី ដល់ឆ្នាំថ្មី ។

វីដេអូទាំងពីរត្រូវបានចែកចាយយ៉ាងទូលំទូលាយក្នុងបណ្តាញសង្គម ព្រមទាំងបានចូលរួមចែកចាយដោយក្រសួងសុខាភិបាល ក្រសួងអប់រំ និងបណ្តាលក្រសួងនានា និងប្រព័ន្ធសារព័ត៌មានផ្សេងៗទៀត ។ នៅក្នុងទំព័រហ្វេសប៊ុករបស់ក្រសួងសុខាភិបាល វីដេអូក្រោមប្រធានបទ "ផ្កាយ" ទទួលបានការចូលមើលចំនួនជាង ៥៦,០០០ ដង ចំណែកវីដេអូក្រោមប្រធានបទ "ទេវតា" ទទួលបានការចូលមើលចំនួនជាង ៨៩,០០០ ដង គិតត្រឹមខែមករា ឆ្នាំ២០២២ ។

អ្នកប្រើប្រាស់ហ្វេសប៊ុកជាច្រើននាក់ បានបញ្ចេញមតិជួយជំរុញឱ្យប្រជាពលរដ្ឋចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺនេះ ជាក់ស្តែងមានអ្នកប្រើប្រាស់ម្នាក់បានសរសេរថា "ត្រូវតែអនុវត្ត ដើម្បីបង្ការជំងឺទាំងអស់គ្នាកម្ពុជាស៊ូស៊ូ" និងម្នាក់ទៀតបានសរសេរថា "សូមបងប្អូនជនរួមជាតិខ្មែរ ចូលរួមសហការជាមួយរាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ និងបំបាត់ជំងឺកូវីដ-១៩ ឱ្យអស់ពីទឹកដីសុវណ្ណភូមិយើងនេះ..." ។

សម្រាប់យុទ្ធនាការស្តីពីជំងឺកូវីដ-១៩ ទៅថ្ងៃខាងមុខទៀតមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព នៅតែទាញយកអត្ថប្រយោជន៍ពីបណ្តាញសង្គម ជាពិសេសហ្វេសប៊ុកក្នុងការផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋ តាមរយៈការផលិតនូវវីដេអូអប់រំជាច្រើន ក្នុងនោះ មានវីដេអូមួយដែលទទួលបានការចាប់អារម្មណ៍ជាច្រើនពីអ្នកប្រើប្រាស់ហ្វេសប៊ុក គឺវីដេអូស្តីពី ការឆ្លងរីករាលដាលនូវមេរោគកូវីដ-១៩ បំលែងថ្មី និងវិធីការពារខ្លួនពីជំងឺកូវីដ-១៩ ដែលត្រឹមត្រូវ ដែលទទួលបានការចូលមើលមានចំនួនរហូតដល់ទៅជាង ១,៨ លានដង គិតត្រឹមខែមករា ឆ្នាំ២០២២ នេះ ។ ជាក់ស្តែង ការប្រើប្រាស់បណ្តាញសង្គម ត្រូវបានដាក់ចូលទៅក្នុងសេចក្តីណែនាំស្តីពីការអនុវត្តយុទ្ធនាការជាតិ ក្រោមប្រធានបទ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ដោយធ្វើការផ្សព្វផ្សាយតាមបណ្តាញសង្គម ដោយប្រើសារ "រួមគ្នាទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩" ព្រមទាំងមានការអញ្ជើញតារាសិល្បៈ គ្រូពេទ្យ អ្នកមានឥទ្ធិពលក្នុងការចូលរួមចែកចាយសារខាងលើ និងផ្តល់បទសម្ភាសអំពីសារៈសំខាន់នៃការចូលរួមទទួលខុសត្រូវរបស់បុគ្គល ក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ៕




## ផ្សេងៗ ស្តីពីការផ្លាស់ប្តូរឥរិយាបថ និងការលើកកម្ពស់សុខភាព

១) សេចក្តីណែនាំស្តីពីការអនុវត្តវិធានការបង្ការការចម្លងជំងឺកូវីដ-១៩ សម្រាប់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ - NCHP

២) សៀវភៅអប់រំសុខភាពស្តីពីជំងឺកូវីដ-១៩ - NCHP

៣) ល្បែងក្តារបន្ទះ "ធ្វើថ្ងៃនេះ កុំចាំស្អែក" - UNICEF

៤) សាលារៀននិងគ្រឹះស្ថានអប់រំ ជាកន្លែងប្រមូលផ្តុំក្នុងការផ្លាស់ប្តូរទម្លាប់ ផ្នត់គំនិត និងឥរិយាបថរបស់កុមារនិងយុវជនចំពោះអនាម័យនិងបរិស្ថាន - MoE

៥) ការប្រើអំណាចនៃការនិយាយរឿង "ដើម្បីបង្កើតការផ្លាស់ប្តូរឥរិយាបថ" (ជាភាសាអង់គ្លេស) – PSI